## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្វាយរៀង

លេខ១៥៤០ [illegible]

ស្វាយរៀង, ថ្ងៃទី១២ ខែ កញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០១៧

-យោងសេចក្តីជូនដំណឹងលេខ៧៧៩សជណ/គ.ជ.អ.បចុះថ្ងៃទី២៦ខែសីហាឆ្នាំ២០១៦ ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្តស្វាយរៀង នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃ នៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣៖អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះអនុគណៈកម្មការបុរេលក្ខណសម្បត្តិ នឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការនិងវិនិយោគ នៃសាលាខេត្តស្វាយរៀង ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង៥ល្ងាច។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។

អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅការិយាល័យគាំទ្រមូលដ្ឋាន ចំណុះទីចាត់ការផែនការនិងវិនិយោគ នៃសាលាខេត្តស្វាយរៀង ឬអាចទាញយកពីគេហទំព័ររបស់គ.ជ.អ.ប(http://ncdd.gov.kh) ដោយឥតបង់ថ្លៃ។

ជ.អភិបាលខេត្តស្វាយរៀង

អភិបាលរង

ហ៊ី_រតនៈ